ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

## <u>សម្រេច</u>

**មាត្រា១._**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល លើផ្ទៃដីទំហំ ៥.០០០ហិកតា (ប្រាំពាន់ហិកតា) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅក្នុងឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុវណ្ណ វុទ្ធី (Sovann Vuthy Co., Ltd.) ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដំណាំកៅស៊ូ។

**មាត្រា២._**

តំបន់ប្រើប្រាស់ដោយចីរភាពក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ក្នុងឃុំ ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាដូចខាងក្រោម៖

| No. | X | Y | No. | X | Y |
|---|---|---|---|---|---|
| A | 678 599 | 134 0296 | G | 683 213 | 134 3124 |
| B | 678 980 | 133 8745 | H | 680 470 | 134 2564 |
| C | 684 009 | 134 0002 | I | 678 389 | 134 2860 |
| D | 687 973 | 133 9997 | J | 678 004 | 134 2134 |
| E | 688 809 | 133 9471 | K | 671 000 | 134 2136 |
| F | 688 817 | 134 2885 | L | 671 001 | 134 0683 |

**មាត្រា៣._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទីកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃស្នួល ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់ផ្តល់ជូនក្រុមហ៊ុន សុវណ្ណ វុទ្ធី
( Sovann Vuthy Co., Ltd ) ស្ថិតក្នុងភូមិសាស្ត្រឃុំពីរធ្នូ ស្រុកស្នួល ខេត្តក្រចេះ លើផ្ទៃដី ៥០០០ ហ.ត




អនុក្រឹត្យ លេខៈ ១៥៤ អនក្រ.បក
ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០

សញ្ញាសំគាល់
ចំណុចនិយាមកា
ទីតាំងវិនិយោគ
ផ្លូវជាតិ
ផ្លូវលំ
ស្ទឹង. អូរ
ព្រំប្រទល់តំបន់ការពារធម្មជាតិ

| ID | N | X | Y |
|---|---|---|---|
| 1 | A | 678599 | 1340296 |
| 2 | B | 678880 | 1338745 |
| 3 | C | 684009 | 1340002 |
| 4 | D | 687873 | 1339987 |
| 5 | E | 688800 | 1339471 |
| 6 | F | 688817 | 1342885 |
| 7 | G | 683213 | 1343124 |
| 8 | H | 680470 | 1342564 |
| 9 | I | 678399 | 1342860 |
| 10 | J | 678004 | 1342134 |
| 11 | K | 671000 | 1342136 |
| 12 | L | 671001 | 1340683 |